# សំណួរសាកសួរញឹកញាប់
# អំពីអត្ថប្រយោជន៍របស់អ្នកដែលពង្រីកបន្ថែមក្នុងកម្មវិធី Medi-Cal

1. **តើខ្ញុំនៅបន្តទទួលបានការរ៉ាប់រងដោយ Medi-Cal ដែរឬទេ?**
   បាទ/ចាស។ អ្នកនៅបន្តមាន Medi-Cal ដដែល។ រដ្ឋកំពុងដាក់បន្ថែមនូវអត្ថប្រយោជន៍នានាទៅក្នុងការរ៉ាប់រងនៃ Medi-Cal របស់អ្នក។ អ្នកនឹងមានអត្ថប្រយោជន៍ Medi-Cal ពេញលេញជាច្រើនបន្ថែមទៀត។

2. **ហេតុអ្វីបានជា Medi-Cal របស់ខ្ញុំកំពុងផ្លាស់ប្តូរ?**
   ចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2020 ច្បាប់ថ្មីមួយនៅក្នុងរដ្ឋ California នឹងផ្តល់សេវា Medi-Cal ពេញលេញជូនដល់មនុស្សពេញវ័យវ័យក្មេង ដែលមានលក្ខណៈសម្បត្តិទទួលបានសេវា Medi-Cal និងមានអាយុក្រោម 26 ឆ្នាំ។ ស្ថានភាពអន្តោប្រវេសន៍ ពុំមែនជាបញ្ហាអ្វីនោះទេ។

3. **តើអ្វីទៅជាសេវា Medi-Cal ពេញលេញ?**
   Medi-Cal ផ្តល់ការថែទាំសុខភាពដោយឥតគិតថ្លៃ ឬមានតម្លៃទាបជូនដល់ពលរដ្ឋមួយចំនួនដែលរស់នៅក្នុងរដ្ឋ California។ សេវា Medi-Cal ពេញលេញ រ៉ាប់រងលើសេវាផ្សេងទៀតក្រៅពីការថែទាំសុខភាពសង្គ្រោះបន្ទាន់។ សេវានេះ ផ្តល់ជូននូវការថែទាំវេជ្ជសាស្ត្រ ទន្តសាស្ត្រ សុខភាពផ្លូវចិត្ត ការពន្យាកំណើត និងការថែទាំគំហើញ(ភ្នែក)។ សេវា Medi-Cal ពេញលេញ ក៏រ៉ាប់រងផងដែរលើការព្យាបាលសម្រាប់ការសេពគ្រឿងស្រវឹង និងគ្រឿងញៀន ថ្នាំពេទ្យដែលវេជ្ជបណ្ឌិតរបស់អ្នកចេញវេជ្ជបញ្ជាជូន និងសេវាជាច្រើនទៀត។ សេវានេះក៏អាចផ្តល់ជូនផងដែរនូវការដឹកជញ្ជូនទៅជួបវេជ្ជបណ្ឌិត និងការជួបពិនិត្យធ្មេញ និងការទៅបើកថ្នាំ។ អ្នកនឹងទទួលបានវេជ្ជបណ្ឌិតថែទាំបឋមម្នាក់។ អ្នកអាចទទួលបានការបញ្ជូនបន្តទៅកាន់គ្រូពេទ្យឯកទេស ប្រសិនបើចាំបាច់។ ដើម្បីឈ្វេងយល់បន្ថែមអំពីអត្ថប្រយោជន៍នៃសេវា Medi-Cal ពេញលេញ សូមអញ្ជើញចូលទៅកាន់៖
   https://www.dhcs.ca.gov/services/medi-cal/Pages/Medi-Cal__EHB_Benefits.aspx

   សេវា Medi-Cal ពេញលេញ គឺខុសគ្នាពីសេវា Medi-Cal មិនពេញលេញ ដែលអ្នកមានក្នុងពេលនេះ។ សេវា Medi-Cal មិនពេញលេញ រ៉ាប់រងលើសេវាកម្មដែលមានដែនកំណត់តែប៉ុណ្ណោះ។ សេវានេះ ពុំរ៉ាប់រងលើឱសថ ឬការថែទាំបឋមនោះទេ។ ប្រសិនបើអ្នកមានសេវា Medi-Cal ដែលមានដែនកំណត់ពាក់ព័ន្ធនឹងការមានផ្ទៃពោះ នោះអ្នកនឹងទទួលបានអត្ថប្រយោជន៍នៃសេវា Medi-Cal ពេញលេញ ប្រសិនបើសេវាទាំងនោះមានភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ។

4. **ចុះប្រសិនបើខ្ញុំជិតចូលដល់អាយុ 26 ឆ្នាំវិញ តើខ្ញុំត្រូវធ្វើដូចម្តេច?**
   អ្នកនឹងទទួលបានសេវា Medi-Cal ពេញលេញ រហូតដល់អ្នកមានអាយុ 26 ឆ្នាំ។ នេះអាស្រ័យលើខោនធីដែលអ្នករស់នៅ ប្រសិនបើអ្នកនឹងឈានចូលដល់អាយុ 26 ឆ្នាំ នៅចន្លោះថ្ងៃទី2 ខែមករា ឆ្នាំ2020 និងថ្ងៃទី30 ខែមិថុនា ឆ្នាំ2020 អ្នកប្រហែលជាអាចជ្រើសរើសបន្តស្ថិតនៅក្នុងកម្មវិធី fee-for-service Medi-Cal បាន ឬចុះឈ្មោះនៅក្នុងគម្រោងសុខភាពរបស់ Medi-Cal។

5. **តើខ្ញុំនឹងប្រើប្រាស់សេវា Medi-Cal ពេញលេញថ្មីរបស់ខ្ញុំដោយរបៀបណា?**
   លើកលែងតែអ្នកឈានចូលដល់អាយុ 26 ឆ្នាំ នៅចន្លោះពីថ្ងៃទី2 ខែមករា ឆ្នាំ2020 និងថ្ងៃទី30 ខែមិថុនា ឆ្នាំ 2020 បើពុំដូចនេះទេ អ្នកនឹងត្រូវចុះឈ្មោះនៅក្នុងគម្រោងសុខភាពរបស់ Medi-Cal នៅពេលណាដែលអ្នកមានសេវា Medi-Cal ពេញលេញ។ នៅមុនពេលដែលអ្នកចុះឈ្មោះនៅក្នុងគម្រោងសុខភាពរបស់ Medi-Cal អ្នកនឹងទទួលបានអត្ថប្រយោជន៍តាមរយៈ fee-for-service (ធម្មតា) របស់ Medi-Cal។

នៅក្នុងគម្រោងសុខភាពរបស់ Medi-Cal អ្នកអាចទៅជួបវេជ្ជបណ្ឌិតដែលធ្វើការជាមួយនឹងគម្រោងរបស់អ្នកបាន។ អ្នកអាចទទួលបានការពិនិត្យសុខភាព ជួបគ្រូពេទ្យឯកទេស ទទួលបានការថែទាំសម្រាប់ស្ថានភាពជំងឺរ៉ាំរ៉ៃ ដូចជា ជំងឺទឹកនោមផ្អែម ឬទទួលការវះកាត់ជាដើម។ គម្រោងសុខភាពរបស់ Medi-Cal នឹងរ៉ាប់រងលើសេវាដែលមានភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ។

6. **តើអ្វីទៅជាគម្រោងសុខភាពរបស់ Medi-Cal?**
   គម្រោងសុខភាពរបស់ Medi-Cal គឺជាគម្រោងធានារ៉ាប់រងសុខភាពដែលរ៉ាប់រងលើសេវានានារបស់ Medi-Cal។ គម្រោងនេះ សហការជាមួយអ្នកផ្តល់សេវាដើម្បីធ្វើឱ្យប្រាកដថា អ្នកទទួលបានសេវាដែលអ្នកត្រូវការដើម្បីបន្តមានសុខភាពល្អ។ គម្រោងសុខភាពរបស់ Medi-Cal សហការជាមួយវេជ្ជបណ្ឌិតរបស់អ្នកដើម្បីគ្រប់គ្រងលើការថែទាំរបស់អ្នក។ នៅពេលណាដែលអ្នកស្ថិតនៅក្នុងគម្រោងសុខភាពរបស់ Medi-Cal គម្រោងរបស់អ្នកផ្តល់ជូនស្ទើរតែគ្រប់សេវាថែទាំសុខភាពទាំងអស់របស់អ្នក។

7. **តើខ្ញុំអាចជ្រើសរើសគម្រោងសុខភាពរបស់ Medi-Cal បានដោយរបៀបណា?**
   ជម្រើសគម្រោងសុខភាពរបស់ Medi-Cal របស់អ្នក គឺអាស្រ័យលើខោនធីដែលអ្នករស់នៅ។ ក្រោយពីអ្នកផ្លាស់ប្តូរទៅកាន់សេវា Medi-Cal ពេញលេញ អ្នកនឹងទទួលបានលិខិតមួយច្បាប់តាមប្រៃសណីយ៍។ គម្រោងនេះនឹងប្រាប់អ្នកឲ្យបានដឹងអំពីជម្រើសគម្រោងសុខភាពរបស់ Medi-Cal របស់អ្នក និងរបៀបចុះឈ្មោះ។ ប្រសិនបើអ្នកមានវេជ្ជបណ្ឌិត ឬគ្លីនិកណាមួយក្នុងពេលនេះ សូមសាកសួរថាតើពួកគេធ្វើ ការជាមួយគម្រោងសុខភាពរបស់ Medi-Cal ណាមួយនៅក្នុងខោនធីរបស់អ្នក។ ប្រសិនបើអ្នកចង់បន្តស្ថិតនៅជាមួយវេជ្ជបណ្ឌិត ឬគ្លីនិកនោះ អ្នកអាចជ្រើសរើសគម្រោងសុខភាពរបស់ Medi-Cal នោះបាន។

   ប្រសិនបើអ្នកមានអាការៈរោគស្មុគ្រស្មាញ ហើយឃើញថាវេជ្ជបណ្ឌិតឬគ្លីនិកណាមួយពុំបានសហការជាមួយគម្រោងសុខភាពរបស់ Medi-Cal នៅក្នុងខោនធីរបស់អ្នកនោះទេ សូមបំពេញនិងផ្ញើទម្រង់បែបបទ "សំណើសុំការលើកលែងផ្នែកវេជ្ជសាស្ត្រ" ដែលមានផ្តល់ជូនមកជាមួយកញ្ចប់ឯកសារជូនដំណឹង។ អ្នកអាចទទួលបានជំនួយពីវេជ្ជបណ្ឌិត ឬគ្លីនិករបស់អ្នក ឬពីអ្នកតស៊ូមតិណាម្នាក់។ ប្រសិនបើអ្នករស់នៅក្នុងខោនធីដែលផ្តល់សេវា Medi-Cal តាមរយៈ County Organized Health System (COHS) អ្នកមិនអាចស្នើសុំការលើកលែងផ្នែកវេជ្ជសាស្ត្របាននោះទេ។ នេះគឺដោយសារតែពុំមានអ្នកផ្តល់សេវា fee-for-service នោះទេ។ គម្រោងរបស់ COHS នឹងធ្វើការទាក់ទងទៅអ្នក។ ពួកគេនឹងផ្ញើឯកសារចុះឈ្មោះជូនដល់អ្នក។

   ប្រសិនបើអ្នកពុំជ្រើសរើសគម្រោងសុខភាពណាមួយរបស់ Medi-Cal នោះ Medi-Cal នឹងជ្រើសរើសគម្រោងសុខភាពមួយរបស់ Medi-Cal នៅក្នុងខោនធីរបស់អ្នកជូនអ្នក។ ជារៀងរាល់ខែ អ្នកមានសិទ្ធិធ្វើការផ្លាស់ប្តូរគម្រោងសុខភាព Medi-Cal របស់អ្នកបាន។

   ប្រសិនបើអ្នកចង់ផ្លាស់ប្តូរគម្រោងរបស់អ្នក សូមទូរសព្ទទៅ Health Care Options តាមរយៈលេខ **1-800-430-4263** (TTY 1-800-430-7077)។ ឬអញ្ជើញចូលទៅកាន់ https://www.healthcareoptions.dhcs.ca.gov។ ប្រសិនបើអ្នកផ្លាស់ប្តូរគម្រោងសុខភាព Medi-Cal របស់អ្នក អ្នកត្រូវចុះឈ្មោះនៅក្នុងគម្រោងសុខភាពមួយផ្សេងទៀតរបស់ Medi-Cal នៅក្នុងខោនធីដដែល។ អ្នកមិនអាចត្រឡប់ទៅប្រើ fee-for-service វិញបានទេ។

8. **តើខ្ញុំអាចទទួលបានការថែទាំនៅមុនពេលដែលខ្ញុំស្ថិតនៅក្នុងគម្រោងសុខភាពរបស់ Medi-Cal បានយ៉ាងដូចម្តេច?**
   ក្នុងខែដែលអ្នកទទួលបានសេវា Medi-Cal ពេញលេញ អ្នកនឹងទទួលបាន fee-for-service Medi-Cal រហូតទាល់តែអ្នកត្រូវបានចុះឈ្មោះនៅក្នុងគម្រោងសុខភាពរបស់ Medi-Cal។ អ្នកអាចទៅជួបវេជ្ជបណ្ឌិតណាម្នាក់ដែលទទួលយកកម្មវិធី fee-for-service Medi-Cal។ ដើម្បីស្វែងរកវេជ្ជបណ្ឌិតណាម្នាក់

សូមសាកសួរការិយាល័យសុខុមាលភាពខោនធីក្នុងតំបន់របស់អ្នកសម្រាប់បញ្ជីឈ្មោះអ្នកផ្តល់សេវា។ នៅពេលអ្នកទូរសព្ទទៅការិយាល័យវេជ្ជបណ្ឌិត សូមសាកសួរថាតើពួកគេទទួលយកអ្នកជំងឺដែលប្រើ "Medi-Cal fee-for-service" ថ្មីដែរឬទេ។ អ្នកក៏អាចប្រើប្រាស់បញ្ជីឈ្មោះវេជ្ជបណ្ឌិតតាមប្រព័ន្ធអនឡាញ នៅក្នុងកម្មវិធី Medi-Cal fee-for-service បានផងដែរ។

**9. តើនរណានឹងក្លាយជាវេជ្ជបណ្ឌិតរបស់ខ្ញុំ នៅពេលខ្ញុំស្ថិតនៅក្នុងគម្រោងសុខភាពរបស់ Medi-Cal?**

នៅពេលដែលអ្នកត្រូវបានចុះឈ្មោះនៅក្នុងគម្រោងសុខភាពរបស់ Medi-Cal អ្នកចាំបាច់ត្រូវតែជ្រើសរើសវេជ្ជបណ្ឌិតថែទាំបឋមម្នាក់ ដែលធ្វើការជាមួយគម្រោងសុខភាព Medi-Cal របស់អ្នក។ អ្នកអាចសាកសួរវេជ្ជបណ្ឌិតបច្ចុប្បន្នរបស់អ្នកថាតើពួកគាត់ធ្វើការនៅក្នុងគម្រោងសុខភាពរបស់ Medi-Cal ណាមួយនៅក្នុងខោនធីរបស់អ្នកដែរឬទេ។ ប្រសិនបើវេជ្ជបណ្ឌិតរបស់អ្នក ធ្វើការនៅក្នុងគម្រោងសុខភាពណាមួយរបស់ Medi-Cal នៅក្នុងខោនធីរបស់អ្នក អ្នកប្រហែលជាអាចរក្សាទុកវេជ្ជបណ្ឌិតរបស់អ្នកបាន ដោយធ្វើការជ្រើសរើសគម្រោងសុខភាពរបស់ Medi-Cal ដែលពួកគេធ្វើការជាមួយ។ បន្ទាប់មកទៀត ជ្រើសរើសវេជ្ជបណ្ឌិតនោះ នៅពេលអ្នកចុះឈ្មោះជាមួយគម្រោងនោះ។

ប្រសិនបើអ្នកត្រូវការវេជ្ជបណ្ឌិតណាម្នាក់ នោះគម្រោងសុខភាពរបស់ Medi-Cal នឹងប្រាប់អ្នកអំពីកន្លែងដែលត្រូវស្វែងរកបញ្ជីឈ្មោះវេជ្ជបណ្ឌិតតាមប្រព័ន្ធអនឡាញ។ អ្នកអាចស្នើសុំពួកគេឲ្យផ្ញើបញ្ជីឈ្មោះវេជ្ជបណ្ឌិតតាមប្រៃសណីយ៍មកកាន់អ្នកក៏បាន។ ប្រសិនបើអ្នកមិនជ្រើសរើសវេជ្ជបណ្ឌិតណាម្នាក់ទេ គម្រោងនេះ នឹងជ្រើសរើសវេជ្ជបណ្ឌិតម្នាក់សម្រាប់អ្នក។ អ្នកអាចផ្លាស់ប្តូរវេជ្ជបណ្ឌិតរបស់អ្នកបានគ្រប់ពេលទាំងអស់។ សម្រាប់ជំនួយក្នុងការស្វែងរកវេជ្ជបណ្ឌិតណាម្នាក់ ឬដើម្បីធ្វើការផ្លាស់ប្តូរវេជ្ជបណ្ឌិត សូមទូរសព្ទទៅផ្នែកសេវាសមាជិកនៃគម្រោងសុខភាពរបស់ Medi-Cal របស់អ្នក។ ប្រសិនបើអ្នកស្ថិតនៅក្នុងខោនធីនៃ COHS ណាមួយ អ្នកអាចទូរសព្ទទៅផ្នែកសេវាសមាជិកនៃគម្រោងសុខភាពរបស់ COHS Medi-Cal នៅក្នុងខោនធីរបស់អ្នកបាន។ សាកសួរថាតើអ្នកនៅបន្តអាចទៅជួបជាមួយវេជ្ជបណ្ឌិតរបស់អ្នកបានដែរឬទេ នៅពេលអ្នកចុះឈ្មោះនៅក្នុងគម្រោងសុខភាពរបស់ Medi-Cal។

**10. តើខ្ញុំអាចរក្សាទុកវេជ្ជបណ្ឌិតរបស់ខ្ញុំបានទេ ប្រសិនបើវេជ្ជបណ្ឌិតរបស់ខ្ញុំមិនធ្វើការជាមួយគម្រោងសុខភាពណាមួយរបស់ Medi-Cal?**

ប្រសិនបើអ្នកបានជួបពិគ្រោះជំងឺជាមួយវេជ្ជបណ្ឌិតណាម្នាក់ក្នុងរយៈពេល 12 ខែ ចុងក្រោយនេះ ហើយវេជ្ជបណ្ឌិតរូបនោះ ពុំបានធ្វើការជាមួយគម្រោងសុខភាពរបស់ Medi-Cal អ្នកអាចស្នើសុំការបន្តការថែទាំបាន។ ប្រសិនបើវេជ្ជបណ្ឌិត និងគម្រោងសុខភាព Medi-Cal របស់អ្នក យល់ព្រមធ្វើការរួមគ្នា នេះមានន័យថាអ្នកប្រហែលជាអាចបន្តទៅជួបពិគ្រោះជំងឺជាមួយវេជ្ជបណ្ឌិតរបស់អ្នកបានក្នុងរយៈពេល 12 ខែ បន្ថែមទៀត។

ប្រសិនបើអ្នកចង់ទទួលបានការបន្តការថែទាំ សូមទូរសព្ទទៅផ្នែកសេវាសមាជិកនៃគម្រោងសុខភាពរបស់ Medi-Cal។ ប្រសិនបើអ្នកមានអាការៈធាគស្មុគស្មាញ ហើយវេជ្ជបណ្ឌិតរបស់អ្នកមិនមែនជាផ្នែកមួយនៃគម្រោងសុខភាពរបស់ Medi-Cal នៅក្នុងខោនធីរបស់អ្នកទេ អ្នកអាចបំពេញទម្រង់បែបបទ "សំណើសុំការលើកលែងផ្នែកវេជ្ជសាស្ត្រ" ដើម្បីឲ្យអ្នកអាចបន្តជួបពិគ្រោះជំងឺជាមួយវេជ្ជបណ្ឌិតរបស់អ្នកបាន។

**11. តើខ្ញុំនឹងត្រូវបង់ថ្លៃសហបង់ប្រាក់ដែរឬទេ?**

ទេ។ ពុំមានសហបង់ប្រាក់នោះទេ។ គម្រោងសុខភាពរបស់ Medi-Cal រ៉ាប់រងរាល់ថ្លៃចំណាយវេជ្ជសាស្ត្រទាំងអស់ដែលមានលក្ខណៈចាំបាច់ផ្នែកវេជ្ជសាស្ត្រ។

**12. តើខ្ញុំនឹងមាន Share of Cost (SOC) ដែរឬទេ?**

វាអាស្រ័យលើស្ថានភាពជាក់ស្តែង។ ប្រសិនបើអ្នកបង់ថ្លៃ SOC ណាមួយក្នុងពេលនេះ អ្នកនឹងត្រូវបន្តបង់ថ្លៃ SOC។

## 13. តើមានសេវាកម្មផ្សេងទៀតអ្វីខ្លះដែលខ្ញុំអាចទទួលបាន?

### សេវាទន្តសាស្ត្រ

អ្នកអាចទទួលបានសេវាទន្តសាស្ត្រតាមរយៈ Medi-Cal។

- ប្រសិនបើអ្នករស់នៅក្នុងខោនធី Sacramento អ្នកនឹងទទួលបានសេវានានាតាមរយៈគម្រោង Medi-Cal Dental Managed Care។ ដើម្បីឈ្វេងយល់បន្ថែមអំពីគម្រោង Medi-Cal Dental Managed Care សូមទូរសព្ទទៅ Health Care Options តាមរយៈលេខ 1-800-430-4263 (TTY: 1-800-430-7077)។ ឬអ្នកអាចបំពេញទម្រង់បែបបទជម្រើសសេវាទន្តសាស្ត្រនៅក្នុងកញ្ចប់ជម្រើសការចុះឈ្មោះរបស់អ្នកក៏បាន។

- ប្រសិនបើអ្នករស់នៅក្នុងខោនធី Los Angeles អ្នកអាចទទួលបានសេវានានាតាមរយៈ Medi-Cal Dental Program តាមរយៈសេវាទន្តសាស្ត្ររបស់ fee-for-service ឬគម្រោងរបស់ Medi-Cal Dental Managed Care។ ដើម្បីឈ្វេងយល់បន្ថែមអំពីការចុះឈ្មោះក្នុងគម្រោង Medi-Cal Dental Managed Care សូមទូរសព្ទទៅ Health Care Options តាមរយៈលេខ 1-800-430-4263 (TTY: 1-800-430-7077)។ ឬអ្នកអាចបំពេញទម្រង់បែបបទជម្រើសសេវាទន្តសាស្ត្រនៅក្នុងកញ្ចប់ជម្រើសការចុះឈ្មោះរបស់អ្នកក៏បាន។

- សម្រាប់ខោនធីដទៃទៀត អ្នកនឹងទទួលបានសេវាទន្តសាស្ត្ររបស់ fee-for-service (កម្មវិធី Medi-Cal ធម្មតាសម្រាប់សេវាទន្តសាស្ត្រ) តាមរយៈ Medi-Cal Dental Program។ អ្នកនឹងត្រូវទៅជួបអ្នកផ្តល់សេវាទន្តសាស្ត្រដែលទទួលយកសេវាទន្តសាស្ត្ររបស់ Medi-Cal។ ដើម្បីស្វែងរកអ្នកផ្តល់សេវាទន្តសាស្ត្រ អ្នកអាចហៅទូរសព្ទទៅមជ្ឈមណ្ឌលសេវាអតិថិជនផ្នែកទន្តសាស្ត្ររបស់ Medi-Cal តាមរយៈលេខ 1-800-322-6384 (TTY: 1-800-735-2922) ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 8:00 ព្រឹកដល់ម៉ោង 5:00 ល្ងាច។ ការហៅទូរសព្ទនេះ ពុំគិតថ្លៃនោះទេ។ អ្នកក៏អាចស្វែងរកអ្នកផ្តល់សេវាទន្តសាស្ត្របានផងដែរនៅលើគេហទំព័ររបស់ Medi-Cal Dental Program’s Smile, California៖ http://smilecalifornia.org/។

### ការពន្យាកំណើត

ការពន្យាកំណើតរួមបញ្ចូលនូវសេវាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ។ សេវានានារួមមានការពន្យារកំណើត ការធ្វើតេស្តនិងការព្យាបាលជំងឺកាមរោគ សេវាសម្រាប់អ្នកមានផ្ទៃពោះ និងការរំលូតកូន។ ក្នុងនាមជាអ្នកទទួលអត្ថប្រយោជន៍ម្នាក់របស់ Medi-Cal អ្នកមានសិទ្ធិក្នុងការជ្រើសរើសអ្នកផ្តល់សេវាការពន្យាកំណើតណាមួយបាន។ នេះរួមបញ្ចូលទាំងអ្នកផ្តល់សេវានៅក្រៅផែនការរបស់អ្នកផងដែរ។ សូមទាក់ទងទៅផែនការសុខភាពរបស់ Medi-Cal របស់អ្នកដើម្បីឈ្វេងយល់បន្ថែម។

### សេវាសុខភាពផ្លូវចិត្ត

ប្រសិនបើអ្នកត្រូវការសេវាសុខភាពផ្លូវចិត្ត សូមពិភាក្សាជាមួយគម្រោងសុខភាព Medi-Cal ថ្មីរបស់អ្នក ឬវេជ្ជបណ្ឌិតរបស់អ្នក។ អ្នកអាចនឹងទទួលបានសេវាសុខភាពផ្លូវចិត្តតាមរយៈគម្រោងសុខភាពថ្មីរបស់ Medi-Cal។ ឬគម្រោងនេះ អាចណែនាំអ្នកបន្តទៅកាន់គម្រោងសុខភាពផ្លូវចិត្តរបស់ Medi-Cal នៅក្នុងខោនធីរបស់អ្នកសម្រាប់សេវាសុខភាពផ្លូវចិត្ត។ អ្នកក៏អាចស្វែងរកសេវាសុខភាពផ្លូវចិត្តបានផងដែរតាមរយៈគម្រោងសុខភាពផ្លូវចិត្តរបស់ខោនធីអ្នក ដោយពុំចាំបាច់មានការបញ្ជូនបន្តនោះទេ។

### សេវាព្យាបាលការសេពគ្រឿងស្រវឹង និងគ្រឿងញៀន

ប្រសិនបើអ្នកកំពុងប្រឈមនឹងបញ្ហាការសេពគ្រឿងស្រវឹង ឬសារធាតុញៀនដទៃទៀត អ្នកអាចទទួលបានការវាយតម្លៃដើម្បីពិនិត្យមើលថាតើអ្នកមាន substance use disorder (SUD) ណាមួយដែរឬទេ។ SUD គឺ

ជាជំងឺខួរក្បាលលាប់ឡើងវិញរ៉ាំរ៉ៃដែលអាចព្យាបាលបាន។ Medi-Cal រ៉ាប់រងលើសេវា SUD ជាច្រើន។ គម្រោងសុខភាពថ្មី Medi-Cal របស់អ្នកនឹងជួយអ្នកស្វែងរកអ្នកផ្តល់សេវាណាម្នាក់។ ឬអ្នកអាចហៅទូរសព្ទទៅផ្នែកសុខភាពអាកប្បកិរិយារបស់ខោនធីអ្នកសម្រាប់សេវាណាមួយ។

**ការដឹកជញ្ជូនមិនមែនវេជ្ជសាស្ត្រ**
ប្រសិនបើអ្នកពុំមានមធ្យោបាយណាមួយដើម្បីទៅជួបវេជ្ជបណ្ឌិត គ្លីនិក ទន្តបណ្ឌិត ឬដើម្បីទៅបើកថ្នាំ ឬសេវាផ្សេងទៀតដែលរ៉ាប់រងដោយ Medi-Cal ទេ អ្នកអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការដឹកជញ្ជូនមិនមែនវេជ្ជសាស្ត្រ។ នៅពេលណាដែលអ្នកស្ថិតនៅក្នុងគម្រោងសុខភាពរបស់ Medi-Cal សូមទូរសព្ទទៅផ្នែកសេវាសមាជិកដើម្បីស្នើសុំការដឹកជញ្ជូនណាមួយ។ នៅពេលអ្នកស្ថិតនៅក្នុងកម្មវិធី fee-for-service Medi-Cal អ្នកប្រហែលជាអាចស្វែងរកក្រុមហ៊ុនដឹកជញ្ជូនបាននៅ https://www.dhcs.ca.gov/services/medi-cal/Pages/Transportation.aspx។

ប្រសិនបើពុំមានអ្នកផ្តល់សេវាដែលបានចុះបញ្ជីនៅក្នុងតំបន់របស់អ្នកនោះទេ អ្នកអាចស្នើសុំជំនួយដោយផ្ញើអ៊ីម៉ែលទៅ DHCS-Benefits@dhcs.ca.gov។ សូមមេត្តា **កុំ**ដាក់បញ្ចូលព័ត៌មានផ្ទាល់ខ្លួនទៅក្នុងអ៊ីម៉ែលទីមួយរបស់អ្នក។ បុគ្គលិករបស់ Department of Health Care Services (DHCS) នឹងធ្វើការឆ្លើយតបទៅវិញតាមអ៊ីម៉ែលដែលមានសុវត្ថិភាព។ ពួកគេនឹងសាកសួរអំពីព័ត៌មានរបស់អ្នក។ វាអាចជួយដល់ការស្នើសុំសេវាបានយ៉ាងតិចប្រាំថ្ងៃនៅមុនការណាត់ជួបរបស់អ្នក។

**14. តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែម ឬជំនួយដោយរបៀបណា?**
សូមទូរសព្ទទៅ Department of Health Care Services (DHCS) Medi-Cal តាមខ្សែទូរសព្ទផ្តល់ជំនួយតាមរយៈលេខ 1-800-541-5555។ ការហៅទូរសព្ទនេះ ជាការហៅទូរសព្ទក្នុងប្រព័ន្ធឥតគិតថ្លៃ។ អ្នកក៏អាចទូរសព្ទទៅការិយាល័យប្រជាពលរដ្ឋរបស់ DHCS តាមរយៈលេខ 1-888-452-8609 ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 8:00 ព្រឹក ដល់ម៉ោង 5:00 ល្ងាច។ ការហៅទូរសព្ទនេះ ពុំគិតថ្លៃនោះទេ។ ការិយាល័យពលរដ្ឋជួយដល់ពលរដ្ឋដែលមានសេវា Medi-Cal ដើម្បីប្រើប្រាស់សិទ្ធិនិងទំនួលខុសត្រូវរបស់ពួកគេ។

អ្នកក៏អាចឈ្វេងយល់បន្ថែមនៅលើគេហទំព័ររបស់ DHCS នៅ៖ https://www.dhcs.ca.gov/services/medi-cal/eligibility/Pages/YoungAdultExp.aspx

**15. ចុះប្រសិនបើខ្ញុំមានសំណួរពាក់ព័ន្ធនឹងអត្ថប្រយោជន៍ Medi-Cal និងស្ថានភាពអន្តោប្រវេសន៍របស់ខ្ញុំ តើខ្ញុំត្រូវធ្វើដូចម្តេច?**
សូមប្រឹក្សាយោបល់ជាមួយមេធាវីផ្នែកអន្តោប្រវេសន៍របស់អ្នក ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ពាក់ព័ន្ធនឹងសំណួរណាមួយអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នក និងអត្ថប្រយោជន៍របស់ Medi-Cal។ California Department of Social Services (CDSS) ផ្តល់មូលនិធិដល់អង្គការមិនរកប្រាក់កម្រៃដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីផ្តល់សេវាដល់ជនអន្តោប្រវេសន៍ដែលស្នាក់នៅក្នុងរដ្ឋ California។ បញ្ជីឈ្មោះអ្នកផ្តល់សេវា មាននៅលើគេហទំព័ររបស់ CDSS នៅ៖ https://www.cdss.ca.gov/Benefits-Services/More-/Services/Immigration-Services Immigration-Services-Contractors

សម្រាប់ព័ត៌មានបន្ថែមអំពីអន្តោប្រវេសន៍និងធនធាននានា សូមចូលទៅកាន់គេហទំព័រមគ្គុទេសក៍សម្រាប់ជនអន្តោប្រវេសន៍របស់រដ្ឋ California៖ https://immigrantguide.ca.gov/